ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៤៨៩

ចុះថ្ងៃទី ០៧_០៧_២០០៩

សាលដីកា

លេខ : ៩០ "ក្រ.III.ស"

ចុះថ្ងៃទី ០៤_១២_២០១២

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១១_២០១២ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៨៩ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៩ ដែលមាន:

- ជនជាប់ចោទឈ្មោះ[redacted]ប៊ុនហុង ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើត និងរស់នៅ [redacted] ស្រុកព្រៃឈរ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ[redacted]មានកូន ២នាក់ ទោសពីមុនគ្មាន ។

មានមេធាវី[redacted]ម៉េងអ៊ាម ការពារ ។

**ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ និងប្លន់** ប្រព្រឹត្តនៅភូមិតាក្រិត ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៣ និងមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ាង ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅស[redacted] ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

**ដំណើររឿងមានដូចតទៅ**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៩៨ របស់ឈ្មោះ[redacted]ហ៊ាង ថា កាលពីថ្ងៃកើតឈ្មោះ[redacted]

ស្រ៊ុន. ស្រីធា និងខ្លួនបាននាំគ្នាទៅរាំនៅផ្ទះមេភូមិឈ្មោះ [redacted] វ៉ាន់ថន។ ពេលកំពុងរាំមានឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] ប៊ុនហុង សុំខ្លួនរាំពីក្រោយ។ ខ្លួនរាំដល់ម៉ោង ១០យប់ ងងុយគេង ក៏ដើរទៅផ្ទះម្នាក់ឯង ដើរបានចម្ងាយ ៣០ម៉ែត្រ ពីកន្លែងរាំ ឈ្មោះ [redacted] វិចិត្រ បានយកកាំភ្លើងខ្លី និងគ្រាប់បែកមកសំឡុតខ្លួន ហើយចាប់អូសខ្លួនទៅគំនរចំបើង ហើយបោកផ្តួលផ្ទប់ខ្លួននឹងចំបើង និងបោកខ្លួនផ្ទប់នឹងដី ហើយអោបខ្លួនជាប់ ហើយសំឡុតខ្លួនកុំឱ្យស្រែក តែស្រែកវានឹងបាញ់ចោល វាក៏ចាប់សម្រាតខោខ្លួនដល់ត្រឹមជង្គង់ ហើយវាពោបខ្លួនពីលើ ឯជើងវាធាក់ខោខ្លួនទាំងវែង និងខ្លីរបូតអស់ ហើយវាចាប់ រំលោភខ្លួនរហូតបានសម្រេច។ ឈ្មោះ [redacted] វិចិត្រ រំលោភរួចហើយ ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] ប៊ុនហុង មកចាប់ ខ្លួនផ្តួលរំលោភទៀត តែឈ្មោះ [redacted] វិចិត្រ គ្រាន់តែបានជួយចាប់ផ្តួល រួចដើរចេញបាត់ នៅតែឈ្មោះ [redacted] ប៊ុនហុង ដែល បានរំលោភខ្លួនរហូតបានសម្រេច។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៣ ត ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទរំលោភ សេពសន្ថវៈលើស្ត្រីភេទ ប្រព្រឹត្តនៅ[redacted]ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ តាមមាត្រា ៣៣ ចំណុច ២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ប៊ុនហុង** ដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទរំលោភ សេពសន្ថវៈ និងប្លន់ទ្រព្យសម្បត្តិ ប្រព្រឹត្តនៅ[redacted]ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ តាមមាត្រា ៣៣ មាត្រា ៦៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **វិចិត្រ** ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទសមគំនិត រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅ[redacted]ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ តាមមាត្រា ៣៣ មាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤- បង្គាប់ឱ្យឈ្មោះ [redacted] **វិចិត្រ** និងឈ្មោះ [redacted] **ប៊ុនហុង** រួមគ្នាសងប្រាក់ជម្ងឺចិត្តចំនួន ១លាន ៥សែនរៀល និងឱ្យ ឈ្មោះ [redacted] **ប៊ុនហុង** សងមាសបន្ថែម ៤ជី (មាសប្លន់) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហ៊ាង** គ្រប់ចំនួន នៅពេល ដែលសាលក្រមចូលជាស្ថាពរ។

ករណីឈ្មោះខាងលើមិនព្រមសងប្រាក់ធនទណ្ឌឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ចំនួននោះទេ តុលាការនឹងរឹបអូសទ្រព្យសម្បត្តិរបស់អ្នកទាំងពីរលក់ឡាយឡុង ដើម្បីសងប្រាក់ធនទណ្ឌ ឬចាប់ដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ តាមមាត្រា ៧ មាត្រា ៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៥- វត្ថុតាង ស្បែកជើងឡាវ (ផ្ទាត់) ពណ៌ដី ១គូ ខោជើងវែងម៉ាក Paris ពណ៌ទឹកប៊ិចឆ្នូតក្រហម និងអាវខូវ ប៊យដៃខ្លីពណ៌ផ្កាឈូក ១ ត្រូវរឹបអូស និងបំផ្លាញចោល។

៦- សាលក្រមនេះប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទទាំងបីនាក់ និងដើមបណ្តឹងរដ្ឋប្បវេណី។ បើភាគី ណាមិនសុខចិត្ត បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប៊ុនហុង ប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៣ គ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣០ ខ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប៊ុនហុង ទុកជាត្រឹមត្រូវតាមទម្រង់ តែទាស់នឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៣ គ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ចាម ទុកជា បានការពេញទាំងមូល។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនហុង និងដើមបណ្តឹងរដ្ឋប្បវេណី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ប៊ុនហុង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣០ ខ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## **<u>នាពេលសវនាការ</u>**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនហុង បានឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍សុំឱ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោស ព្រោះសាលាដំបូងបានសម្រេចផ្តន្ទាទោសខ្លួនធ្ងន់ពេក។ ខ្លួនពិតជាបានរំលោភលើជនរងគ្រោះពិតមែន ពេលខ្លួនទៅចាប់

រំលោភនោះ ខ្លួនទៅតាមគេតែម្នាក់ឯងទេ ពេលនោះខ្លួនស្រវឹង។ នៅថ្ងៃកើតហេតុនោះខ្លួនទៅជាមួយឈ្មោះ [redacted] ចំពោះ ឈ្មោះ យឹម វិចិត្រ ខ្លួនអត់ដឹងទេ។ ចម្លើយនៅប៉ូលីសខ្លួនទទួលស្គាល់ទាំងអស់។ សំណូមពរ សុំតុលាការ ឱ្យខ្លួនរួចផុតពីបទ ចោទ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ៊ាង ឆ្លើយថា: ឈ្មោះ [redacted] វិចិត្រ ជាអ្នករំលោភខ្លួនមុន បន្ទាប់មកឈ្មោះ [redacted] ប៊ុនហុង រំលោភខ្លួនក្រោយ តែអ្នកដែលរំលោភ និងឆក់ផ្ដាច់ក្រវិល គឺឈ្មោះ [redacted] វិចិត្រ។ ខ្លួនឆ្លើយដាក់ឈ្មោះ [redacted] ប៊ុនហុង ព្រោះខ្លួនខឹងគាត់ដែលគាត់មិនការពារខ្លួន។ កាលពីមុនខ្លួន និងឈ្មោះ [redacted] ប៊ុនហុង ស្រលាញ់គ្នាមែន តែពេលកើតហេតុឈ្មោះ [redacted] វិចិត្រ ចាប់បង្ខំខ្លួន ព្រោះវាមានកាំភ្លើង។ ខ្លួនដឹងថា ឈ្មោះ [redacted] ប៊ុនហុង មានប្រពន្ធហើយ ហើយ ខ្លួនមេម៉ាយ ខ្លួនធ្លាប់បានរួមភេទជាមួយគ្នាច្រើនដងហើយ ហើយមានទំនាក់ទំនងគ្នាតាំងពីនៅកម្លោះក្រមុំ ម្ល៉េះ។ ចំពោះ សំណងទាំងអស់ខ្លួនសុខចិត្តមិនទទួល។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ឃើញថា មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ដោយចម្លើយរបស់ជនជាប់ចោទមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយរបស់ជនរងគ្រោះ ដូច្នេះ សុំឱ្យក្រុមប្រឹក្សាពិចារណាតាម ច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

នៅក្នុងរឿងនេះជនរងគ្រោះបានដកបណ្តឹងហើយ ជនជាប់ចោទ និងជនរងគ្រោះបានព្រមព្រៀងគ្នា ហើយគាត់ដឹងថា អំពើដែលគាត់ប្រព្រឹត្តជាអំពើខុសច្បាប់ តែរឿងនេះមិនអាចថា ជារឿងរំលោភទេ ដោយគាត់ទាំងពីរនាក់ធ្លាប់មានទំនាក់ទំនងស្រលាញ់គ្នា ហើយនៅថ្ងៃកើតហេតុជនជាប់ចោទគាត់មិនដឹងថា ឈ្មោះ [redacted] វិចិត្រ ចាប់រំលោភជនរងគ្រោះទេ គាត់ទៅតាមក្រោយគេទេ ហើយព្រមព្រៀងជាមួយជនរងគ្រោះទេ ដូច្នេះ សុំលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា៖

១- បណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១០ របស់ឈ្មោះ ជា ប៊ុនហុង ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ជនជាប់ចោទបានឆ្លើយសារភាព ខ្លួនពិតជាបានរួមរក្សជាមួយនារី មុំ ហ៊ាង មែន នៅថ្ងៃកើតហេតុ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ ពេលនោះខ្លួនឃើញឈ្មោះ [redacted] វិចិត្រ ទាញនារី មុំ ហ៊ាង នៅកន្លែងស្ងាត់ នៅពេលនាងចេញពី កន្លែងរាំបុណ្យជាភូមិ. ក្រោយមកឈ្មោះ [redacted] វិចិត្រ ចេញផុតពីកន្លែងពុំទូកចំបើង ខ្លួនក៏ចូលទៅរកនារី [redacted] ហ៊ាង ហើយ ក៏បានរួមភេទជាមួយនាង ដោយគ្មានការបង្ខិតបង្ខំទេ គឺប្រព្រឹត្តទៅរហូតបានសម្រេចដោយការព្រមព្រៀង ។

៣- តាមចម្លើយនារី [redacted] ហ៊ាង ថា ខ្លួននឹងឈ្មោះ [redacted] ប៊ុនហុង ធ្លាប់មានទំនាក់ទំនងស្នេហាជាមួយគ្នាតាំងពីនៅវ័យក្មេង ហើយបានបន្តទំនាក់ទំនងរហូតមកដែរ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] វិចិត្រ បានចាប់ទាញខ្លួនយកកាំភ្លើងខ្លីភ្ជង់ខ្លួន ហើយរំលោភសេពសន្ថវៈមែន ខ្លួនមិនហ៊ានស្រែក ព្រោះខ្លាចគេបាញ់សម្លាប់ ឯឈ្មោះ [redacted] ប៊ុនហុង បានរួមរក្សជាមួយ ខ្លួនដោយការព្រមព្រៀងពិតប្រាកដ ពុំមែនមានការបង្ខិតបង្ខំទេ. ខ្លួនសុំដកបណ្តឹង ហើយរាល់សំណងទាំងអស់ព្រមទាំង សំណងខូចខាតផង ខ្លួនមិនទាមទារ និងយកវិញទេ នូវគ្រឿងអលង្ការដែលបានបាត់បង់ទៅ។ ខ្លួនប្តឹង [redacted] ប៊ុនហុង ដោយ ពេលនោះ ប៊ុនហុង ដឹងថា គេចាប់ខ្លួនរំលោភ តែមិនជួយខ្លួនប៉ុណ្ណោះ។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាក្រិត ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តែដោយអនុលោមតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ គួរកែប្រែបទចោទ ជាបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងសម្រេចឡើងវិញ ឱ្យបានត្រឹមត្រូវ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៣០ ខ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី ២ គួរកែប្រែដូចយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ប៊ុនហុង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣០ ខ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការ លើកលែងតែចំណុចទី ២ ត្រូវ៖ ៗ

២-១- កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនហុង ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ទៅជាបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៤០ និងតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ។

២-២- ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ [redacted] **ប៊ុនហុង** ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិតាក្រិត ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ១៩៩៨ បទល្មើសមានចែង និងឱ្យ ផ្តន្ទាទោសតាមមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ។

២-៣- លុបចំណុចទី៤ ស្តីពីសេចក្តីសម្រេចបង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនហុង រួមសងសំណងជម្ងឺចិត្ត និងសងមាសចំនួន ៤ជី ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ចោលជាអសារបង់ តាមឆន្ទៈ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ។ ក្រៅពីនេះទុកនៅដដែល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃនេះតទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤

ក្រឡាបញ្ជី